អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១១

# សេចក្តីអញ្ជើញចូលរួមសវនាការសាធារណៈលើបណ្តឹងសាទុក្ខ ក្នុងសំណុំរឿងក្តីរបស់ "ឌុច" ពីថ្ងៃទី ២៨ ដល់ថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១១

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) មានកិត្តយសសូមគោរពអញ្ជើញសាធារណជន មន្ត្រីការទូត និងតំណាងសារព័ត៌មានជាតិនិងអន្តរជាតិ ចូលរួមសវនាការសាធារណៈលើបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង០០១ ប្រឆាំងនឹង កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលត្រូវចោទប្រកាន់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម ដែលកើតឡើងនៅមន្ទីរ ស-២១ (ទួលស្លែង) និងនៅទីកន្លែងផ្សេងទៀតដែលទាក់ទងគ្នា។

សវនាការសាធារណៈនឹងចាប់ផ្តើមពីថ្ងៃច័ន្ទ ទី**២៨ ខែមីនា ឆ្នាំ២០១១** ហើយនឹងបន្តទៅថ្ងៃអង្គារ ទី២៩ និងថ្ងៃពុធ ទី៣០ ខែមីនា ចាប់ពីម៉ោង ៩:០០ព្រឹក ដល់ម៉ោង ៤:៣០ រសៀល។ ប្រសិនបើសវនាការពុំអាច បញ្ចប់បានក្នុងអំឡុងពេលបីថ្ងៃនេះ សវនាការនឹងបន្តនៅថ្ងៃព្រហស្បតិ៍ ទី៣១ ខែមីនា។ អ.វ.ត.ក ផ្តល់ការ បកប្រែប្រដេញអំពីដំណើរការសវនាការ ជាបីភាសា គឺភាសាខ្មែរ អង់គ្លេស និងបារាំង។

ដើម្បីធានាបាននូវសណ្តាប់ធ្នាប់និងរបៀបរៀបរយនៅក្នុងសាលសវនាការ សាធារណជនទាំងអស់ត្រូវតែ ចូលអង្គុយក្នុងសាលសវនាការយឺតបំផុតត្រឹមម៉ោង ៨:៤៥ ព្រឹក។ សាធារណជនគួរតែមកដល់ អ.វ.ត.ក នៅចន្លោះពីម៉ោង ៧:៣០ ដល់ម៉ោង ៨:០០ ព្រឹក ដើម្បីឲ្យមានពេលវេលាគ្រប់គ្រាន់សម្រាប់ការត្រួតពិនិត្យ ផ្នែកសន្តិសុខ និងចែកប័ណ្ណសម្រាប់ចូល។

សាធារណជនដែលចង់ចូលរួមស្តាប់សវនាការនេះនៅក្នុងសាលសវនាការរបស់ អ.វ.ត.ក ត្រូវតែបង្ហាញ អត្តសញ្ញាណប័ណ្ណដែលមានបិទរូបថត និងឆ្លងកាត់ការត្រួតពិនិត្យសន្តិសុខ។ សាធារណជនត្រូវតែមាន អាកប្បកិរិយាថ្លៃថ្នូរនិងសមរម្យគ្រប់ពេលវេលា និងត្រូវមានសម្លៀកបំពាក់សមរម្យ។ មិនត្រូវប្រើ សម្លៀកបំពាក់ដែលមានពាក្យស្លោកដែលបង្ហាញការគាំទ្រឬការមាក់ងាយដល់ភាគីណាមួយនៃដំណើរការ ឡើយ។ សូមកត់សម្គាល់ថា អ្នកដែលមានអាយុក្រោម១៦ឆ្នាំនឹងមិនត្រូវបានអនុញ្ញាតឲ្យចូលរួមឡើយ

Original EN: 00527483-00527484

ហើយអ្នកដែលមានអាយុចន្លោះពី ១៦ដល់១៨ឆ្នាំ អាចចូលបានលុះត្រាតែមានមនុស្សចាស់មកជាមួយ។ មិនអនុញ្ញាតឲ្យយកទូរស័ព្ទដៃ ម៉ាស៊ីនថតរូប កុំព្យូទ័រយួរដៃ ឧបករណ៍ថតសំឡេង កាបូបធំៗ អាហារ ឬភេសជ្ជៈ ចូលក្នុងសាលសវនាការឡើយ។

អ.វ.ត.ក មានទីតាំងនៅសង្កាត់ចោមចៅ ចម្ងាយ១៦ គីឡូម៉ែត្រពីរាជធានីភ្នំពេញ ខាងឆ្វេងផ្លូវជាតិលេខ៤។ សាធារណជននិងតំណាងសារព័ត៌មានសូមអញ្ជើញចូលតាមច្រកសម្រាប់ភ្ញៀវដែលស្ថិតនៅផ្នែកខាងកើត នៃ អ.វ.ត.ក។

សាធារណជនដែលមកចូលរួមសវនាការអាចចតយានយន្តនៅចំណតយានយន្តដែល អ.វ.ត.ក រៀបចំជូន។ អ.វ.ត.ក ក៏ផ្តល់កៅអីរុញនិងជំនួយផ្សេងៗសម្រាប់ជនពិការដែលចង់ចូលរួមផងដែរ។

**កន្លែងអង្គុយនៅក្នុងសាលសវនាការសាធារណៈ ត្រូវបានរៀបចំដូចខាងក្រោម៖**

**១. ភាគីដើមបណ្តឹងរដ្ឋប្បវេណី** (រួមទាំងអ្នកដែលបានដាក់ពាក្យបណ្តឹងសាទុក្ខ) ៖ **៩០ កៅអី**

ក្នុងករណីដែលកន្លែងអង្គុយទាំងនោះនៅសល់ទំនេររហូតដល់ម៉ោង ៩:០០ ព្រឹក នៃថ្ងៃសវនាការ កន្លែងអង្គុយទាំងនោះនឹងត្រូវរៀបចំសម្រាប់សាធារណជនទូទៅ។

**២. សាធារណជនដែលមកជាក្រុម ៖ ២៣០ កៅអី**

ក្រុមនេះរួមមាន ប្រជាពលរដ្ឋ សិស្ស និស្សិត និងព្រះសង្ឃ ដែលរៀបចំដោយផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក។ ក្នុងករណីដែលកន្លែងអង្គុយទាំងនោះនៅសល់ទំនេររហូតដល់ម៉ោង ៩:០០ ព្រឹក នៃថ្ងៃសវនាការ កន្លែងអង្គុយទាំងនោះនឹងត្រូវរៀបចំសម្រាប់សាធារណជនទូទៅ។

**៣. សាធារណជនទូទៅ ៖ ៥០ កៅអី**

សាធារណជនដែលមានបំណងចូលរួមស្តាប់សវនាការសាធារណៈជាបុគ្គល សូមចុះឈ្មោះជាមុន ដើម្បីទទួលបានកន្លែងអង្គុយក្នុងសាលសវនាការ។ គោលការណ៍នៃការបែងចែកកៅអីសម្រាប់ផ្នែកនេះគឺ អ្នកណាមកមុននឹងទទួលបានកន្លែងអង្គុយមុន។

**៤. តំណាងអង្គការក្រៅរដ្ឋាភិបាល ៖ ៣០ កៅអី** ត្រៀមបម្រុងសម្រាប់តំណាងអង្គការជាតិនិងអន្តរជាតិ ដែលមានកម្មវិធីពាក់ព័ន្ធនឹង អ.វ.ត.ក។ ក្នុងករណីដែលកន្លែងអង្គុយទាំងនោះនៅសល់ទំនេររហូតដល់ម៉ោង ៩:០០ ព្រឹក នៃថ្ងៃសវនាការ កន្លែងអង្គុយទាំងនោះនឹងត្រូវរៀបចំសម្រាប់សាធារណជនទូទៅ។


ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

**៥. មន្ត្រីការទូត និង មន្ត្រីផ្សេងទៀត ៖ ៦០ កៅអី** សម្រាប់មន្ត្រីការទូតមកពីប្រទេសជាមិត្តរបស់ អ.វ.ត.ក រួមទាំងតំណាងប្រទេសម្ចាស់ជំនួយ មន្ត្រីរាជរដ្ឋាភិបាលកម្ពុជា និងអ្នកជំនាញដែលសិក្សាស្រាវជ្រាវអំពី អ.វ.ត.ក។ អ្នកទាំងនោះត្រូវតែចុះឈ្មោះជាមុន។ កាលបរិច្ឆេទចុងក្រោយសម្រាប់ការចុះឈ្មោះគឺ **ថ្ងៃពុធ ទី២៣ ខែមីនា ឆ្នាំ២០១១ វេលាម៉ោង ៤:០០ រសៀល**។ ក្នុងករណីដែលកន្លែងអង្គុយទាំងនោះនៅសល់ ទំនេររហូតដល់ម៉ោង ៩:០០ ព្រឹក នៃថ្ងៃសវនាការ កន្លែងអង្គុយទាំងនោះនឹងត្រូវបានរៀបចំសម្រាប់ សាធារណជនទូទៅ។

**៦. តំណាងសារព័ត៌មាន ៖ ២០ កៅអី (ត្រូវតែចុះឈ្មោះជាមុន)**
អាទិភាពសម្រាប់តំណាងសារព័ត៌មានដែលអង្គុយនៅក្នុងសាលសវនាការគឺ អ្នកសារព័ត៌មានផ្នែកបោះពុម្ព។ តំណាងសារព័ត៌មានដទៃទៀត នឹងត្រូវរៀបចំជូនកន្លែងអង្គុយក្នុងបន្ទប់សារព័ត៌មាននៅជាន់ផ្ទាល់ដី។ តំណាងសារព័ត៌មានដែលមានបំណងទទួលបានកន្លែងអង្គុយក្នុងសាលសវនាការ ត្រូវធ្វើសំណើសុំកន្លែង អង្គុយ ព្រមទាំងចុះឈ្មោះសម្រាប់ការចូលរួមស្តាប់សវនាការផង (សូមមើលព័ត៌មានបន្ថែមខាងក្រោម)។

**ដើម្បីចុះឈ្មោះសុំកន្លែងអង្គុយ សូមទាក់ទងលោក ចិន ហែមវិចិត្រ តាមរយៈ ៖**

សារអេឡិកត្រូនិក: pas@eccc.gov.kh
ទូរស័ព្ទ: ០២៣ ២១៩ ៨១៤ លេខបន្ត ៦០៦៥
ឬទូរស័ព្ទដៃ: ០១២ ៦៩៦ ២២០
ទូរសារ: ០២៣ ២១៩ ៨៤១

**ការអនុញ្ញាតជាផ្លូវការដល់តំណាងសារព័ត៌មាននៅថ្ងៃទី ២៨-៣០ ខែមីនា៖**
តំណាងសារព័ត៌មានទាំងអស់ដែលមានបំណងចូលរួមក្នុងសវនាការសាធារណៈពីថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១ ត្រូវតែចុះឈ្មោះនិងសុំប័ណ្ណព័ត៌មានជាមុន។ នីតិវិធីខាងក្រោមនេះនឹងត្រូវអនុវត្តចំពោះ អ្នកសារព័ត៌មានដែលមានបំណងចូលរួមយកព័ត៌មាននៅក្នុងសវនាការលើបណ្តឹងសាទុក្ខ ៖

ក) អ្នកសារព័ត៌មានដែលបច្ចុប្បន្នកាន់ប័ណ្ណព័ត៌មានមានសុពលភាពជាផ្លូវការរបស់អ.វ.ត.ក ត្រូវចុះ ឈ្មោះនៅផ្នែកកិច្ចការសាធារណៈតាមរយៈការផ្ញើសារអេឡិចត្រូនិចទៅកាន់ PAS@ECCC.GOV.KH។

ខ) អ្នកសារព័ត៌មានដែលបច្ចុប្បន្នកាន់ប័ណ្ណព័ត៌មានជាផ្លូវការរបស់ អ.វ.ត.ក តែផុតកំណត់ ត្រូវបំពេញ ទម្រង់បែបបទសុំប័ណ្ណព័ត៌មានសាជាថ្មី ដោយទាញយកពី

Original EN: 00527483-00527484

(http://www.eccc.gov.kh/english/cabinet/fileUpload /26/ECCC_Accreditation Media_Application_Form.doc) ជាមួយនឹងសំណើសុំចុះឈ្មោះតាមរយៈសារអេឡិចត្រូនិច PAS@ECCC.GOV.KH ។ សូមកុំភ្លេចបញ្ជាក់លេខប័ណ្ណចាស់ដែលផុតកំណត់។

គ) អ្នកសារព័ត៌មានដែលមិនទាន់ទទួលការអនុញ្ញាតជាផ្លូវការពី អ.វ.ត.ក ត្រូវបំពេញនិងដាក់ទម្រង់បែបបទសុំការអនុញ្ញាតជាផ្លូវការសម្រាប់អ្នកសារព័ត៌មាន ដោយអាចទាញយកពី (http://www.eccc.gov.kh/english/cabinet/fileUpload/26/ECCC_Accreditation Media_Application_ Form.doc) ភ្ជាប់រូបថតទម្រង់ jpg មួយសន្លឹក និងសំណើសុំចុះឈ្មោះតាមរយៈសារអេឡិចត្រូនិច រួចផ្ញើមក PAS@ECCC.GOV.KH។

**ថ្ងៃផុតកំណត់សម្រាប់ការចុះឈ្មោះអ្នកសារព័ត៌មាន៖ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១១ វេលាម៉ោង ៤ រសៀល**

Original EN: 00527483-00527484